


# កូហ្វតាសម្រាប់អាហារថ្ងៃត្រង់

ដោយ ខាទ្រីណា មិកហ្វៀធើរ
( ផ្អែកទៅលើដំណើររឿងពិត )

*ដំណើររឿងនេះបានកើតឡើងនៅ ស.រ.អា. ។*

រ៉ៃយអង្គុយចុះនៅតុអាហារ ហើយបានបើកកញ្ចប់បាយថ្ងៃត្រង់របស់គាត់ ។ គ្រួសាររបស់គាត់ទើបផ្លាស់លំនៅមក ហើយនេះជាថ្ងៃដំបូងរបស់គាត់នៅសាលារៀនថ្មី ។ ម៉ាក់គាត់បានធ្វើម្ហូបអាមេនីដែលគាត់ចូលចិត្ត គឺកូហ្វតា ។ គាត់រំភើបចិត្តនឹងញ៉ាំវា !

រ៉ៃយបានបកក្រដាស ដែលរុំជុំវិញកូហ្វតានោះចេញ ។ វាដូចជាប្រហិតវែងស្តើងមួយអញ្ចឹង ។ គាត់ចូលចិត្តក្លិនគ្រឿងទេសដែលដុតក្នុងសាច់នោះ ។ ហើយប្រហោងនៅកណ្តាលធ្វើឲ្យវាដូចដាកំពៀតូចមួយអីចឹង ។ គាត់បានដាក់វានៅបបូរមាត់ ហើយផ្លុំ ។ ហើយគាត់ខាំមួយម៉ាត់ ។ ឆ្ងាញ់ណាស់ !

ក្មេងប្រុសម្នាក់ដែលនៅតុទល់មុខនោះបាននិយាយថា« ហេ » ។ « តើឯងកំពុងញ៉ាំរបស់អីនោះចម្លែកម្ល៉េះ ? »

រ៉ៃយមានអារម្មណ៍ថាមុខគាត់ឡើងក្រហម ។ « វាជាអាហារថ្ងៃត្រង់របស់ខ្ញុំ » ។

« តែវាមើលទៅអត់ទំនងសោះ » ។ ក្មេងប្រុសនោះបានសើច ។

រ៉ៃយគ្មានពាក្យនឹងថ្លែងឡើយ ។ គាត់មិនដឹងថាគ្មាននរណាម្នាក់នៅទីនេះញ៉ាំកូហ្វតាទេ ។ គាត់មិនចង់ឲ្យពួកគេគិតថាគាត់ចម្លែកនោះទេ ! ដូច្នេះ គាត់ទុកអាហារថ្ងៃត្រង់របស់គាត់វិញ ហើយរត់ទៅក្រៅដើម្បីសម្រាក ។

ពេលចេញពីរៀន រ៉ៃយឃើញម៉ាក់បើកប្រអប់បាយ ។

រ៉ៃយបាននិយាយថា « ខ្ញុំមិនចង់យកកូហ្វតាទៅសាលារៀនទៀតទេ » ។

« ហេតុអ្វី ? » ម៉ាក់បានសួរ ។ « វាជាម្ហូបដែលកូនចូលចិត្ត » ។

រ៉ៃយបានប្រាប់ពីអ្វីដែលបានកើតឡើងនៅសាលារៀន ។ « វាខ្មាសគេណាស់ម៉ាក់ ! »

ម៉ាក់បាននិយាយថា « ម៉ាក់សោកស្តាយណាស់ដែលរឿងនេះបានកើតឡើង » ។ « មនុស្សភាគច្រើននៅទីនេះមិនធ្លាប់ញ៉ាំកូហ្វតាទេ ។ ចុះបើយើងឲ្យក្មេងផ្សេងទៀតសាកញ៉ាំខ្លះយ៉ាងម៉េចដែរ ? »

« ហេតុអ្វី ? » រ៉ៃយបានសួរ ។ « ពួកគេមិនចង់ញ៉ាំទេ » ។

« តែកូនមិនដឹងទេ លុះត្រាតែកូនសួរគេសិន ! ម៉ាក់ដឹងថាវាពិបាកដើម្បីរាប់អានមិត្តភក្តិថ្មីៗ ។ ប៉ុន្តែយើងទាំងអស់គ្នាគឺជាបុត្រាបុត្រីរបស់ព្រះ ។ ពេលខ្លះយើងគ្រាន់តែត្រូវស្គាល់គ្នាបន្ថែមទៀត » ។

រ៉ៃយបានគិតអំពីវា ។ គាត់មិនចង់ឲ្យគេសើចចំអក ។ ប៉ុន្តែគាត់ចង់ផ្តល់ឱកាសយល់ពីក្មេងដែលនៅអាហារថ្ងៃត្រង់នោះកាន់តែប្រសើរឡើង ។ ហើយកូហ្វតានោះពិតជាឆ្ងាញ់ណាស់ ។

គាត់បានងក់ក្បាល ។ « យល់ព្រម ។ តោះធ្វើបន្ថែមទៀត » ។

នៅថ្ងៃបន្ទាប់នៅពេលអាហារថ្ងៃត្រង់ រ៉ៃយបានដកដង្ហើមធំ ។ គាត់បានអង្គុយចុះជិតក្មេងប្រុសដែលបានសើចចំអកគាត់ ។

រ៉ៃយបានបើកកញ្ចប់បាយថ្ងៃត្រង់របស់គាត់ ។ « តើមានអ្នកណាចង់សាកម្ហូបអាមេនីនេះខ្លះទេ ? »

ក្មេងៗផ្សេងទៀតមកជុំវិញនៅពេលរ៉ៃយបានបកកញ្ចប់កូហ្វតា ។

« ខ្ញុំចង់សាកខ្លះ » ក្មេងប្រុសនោះបាននិយាយ ។

« ខ្ញុំក៏អីចឹងដែរ » ក្មេងស្រីម្នាក់បានបន្ថែម ។ រ៉ៃយបានហុចកូហ្វតាតៗគ្នាដើម្បីឲ្យគ្រប់គ្នាអាចសាកញ៉ាំ ។ បន្ទាប់មកពួកគេទាំងអស់គ្នាខាំមួយម៉ាត់ ។

« ឆ្ងាញ់ណាស់ » ក្មេងប្រុសនោះបាននិយាយ ។ « តើវាឈ្មោះអ្វីទៅ ? »

រ៉ៃយ បាននិយាយថា « កូហ្វតា » ។

« ឆ្ងាញ់ណាស់ ! » ក្មេងប្រុសនោះបានញញឹម ។ « ខ្ញុំឈ្មោះ ចន ។ ចង់លេងជាមួយគ្នាពេលចេញលេងទេ ? »

រ៉ៃយគ្រាន់តែអាចងក់ក្បាលដោយមាត់ពេញដោយម្ហូប ។ ម៉ាក់និយាយត្រូវហើយ—ពួកគេទាំងអស់គ្នាក៏ជាបុត្រាបុត្រីរបស់ព្រះដែរ ។ ហើយនៅទីបំផុតការចែករំលែកបានជួយគាត់មានមិត្តភក្តិ ។●

## សូមធ្វើកូហ្វតាដោយខ្លួនឯងដើម្បីចែករំលែក !

លាយ សាច់ចៀម ឬសាច់គោចិញ្ច្រាំ ១ ផោន ( ០.៥ គក ), ខ្ទឹមបារាំង ១ ( កាត់ជាដុំៗ ) ស្រូវសាលី bulgur ឬកំទេចនំប៉័ង ៣០ក្រាម, ខ្ទឹមស ២ កំពឹស ( ចិញ្ច្រាំឲ្យម៉ត់ ) និង ១ ស្លាបព្រាកាហ្វេនៃម្សៅ cumin, ម្សៅ ground coriander, ម្សៅ paprika, ម្សៅឈើផ្អែម រួមទាំង អំបិល ផងដែរ ។ មូរល្បាយទៅជាដុំវែងៗ ហើយដោតចង្កាក់ដែកចូលដុំនីមួយៗ ។ ( ប្រសិនបើប្អូនប្រើឈើចង្កាក់ សូមត្រាំវាក្នុងទឹកឲ្យបាន ៣០ នាទីសិន ) ។ ដុតនៅសីតុណ្ហភាព ៣៥០°F ( ១៨០ អង្សាសេ ) រយៈពេល ២០ នាទី ឬរហូតដល់សាច់ឆ្អិន ។

